# ធនាគារ ព្រីនស៍ ម.ក

## បញ្ញត្តិ និងលក្ខខណ្ឌសម្រាប់កម្មវិធីបញ្ចុះតម្លៃលើសំបុត្រកុននៅពេលប្រើប្រាស់ប័ណ្ណធនាគារ ព្រីនស៍ (UPI MasterCard Visa) នៅរោងកុន Major Cineplex

ធនាគារ ព្រីនស៍ ម.ក ("**ធនាគារ ព្រីនស៍**") កំពុងដាក់ដំណើរការកម្មវិធីបញ្ចុះតម្លៃលើសំបុត្រកុននៅពេលប្រើប្រាស់ប័ណ្ណធនាគារ ព្រីនស៍ (UPI MasterCard Visa) នៅរោងកុន Major Cineplex ដោយអនុលោមតាមបញ្ញត្តិ និងលក្ខខណ្ឌ ដែលបានចែងនៅទីនេះ ("**កម្មវិធីលើកទឹកចិត្ត**")។ តាមរយៈការចូលរួមកម្មវិធីលើកទឹកចិត្តនេះ អតិថិជន យល់ព្រមអនុវត្តតាមបញ្ញត្តិ និងលក្ខខណ្ឌដូចខាងក្រោម ព្រមទាំងបញ្ញត្តិ និងលក្ខខណ្ឌទូទៅ បញ្ញត្តិ និងលក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណឥណទាន បញ្ញត្តិ និងលក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណ និងបញ្ញត្តិ និងលក្ខខណ្ឌដែលពាក់ព័ន្ធដទៃទៀត៖

១. រាល់អតិថិជនចាស់ និងអតិថិជនថ្មីជារូបវន្តបុគ្គលរបស់របស់ ធនាគារ ព្រីនស៍ ដែលប្រើប្រាស់ប័ណ្ណឥណទាន/ប័ណ្ណឥណពន្ធ ប្រភេទណាមួយ (UPI MasterCard ឬ Vsia) ដែលចេញដោយធនាគារ ព្រីនស៍ រួមទាំងម្ចាស់ប័ណ្ណមេ ឬម្ចាស់ប័ណ្ណរង ("**អ្នកចូលរួម**") អាចចូលរួមកម្មវិធីលើកទឹកចិត្តនេះ។

២. អតិថិជនដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម នឹងទទួលការផ្តល់ជូនពិសេស("**ការផ្តល់ជូន**") ស្របតាមបញ្ញត្តិ និងលក្ខខណ្ឌខាងក្រោម។

<table>
<tr><th rowspan="2">ប្រភេទប្រតិបត្តិការ</th><th rowspan="2">ពាណិជ្ជករ</th><th colspan="2">ការផ្តល់ជូន (ការបញ្ចុះតម្លៃ)</th><th rowspan="2">រយៈពេលកម្មវិធីលើកទឹកចិត្ត</th></tr>
<tr><th>ប្រភេទ Standard</th><th>ប្រភេទ Platinum</th></tr>
<tr><td>រាល់ការទិញសំបុត្រកុនតាមម៉ាស៊ីនឆូតកាត ដោយប្រើប្រាស់ប័ណ្ណធនាគារ ព្រីនស៍ ដូចជាប័ណ្ណ UPI MasterCard និង Visa (ទាំងប័ណ្ណឥណពន្ធ/ប័ណ្ណឥណទាន)<br><br>(ថ្ងៃច័ន្ទ ដល់ថ្ងៃអាទិត្យ)</td><td>គ្រប់សាខារោងកុន Major Cineplex ក្នុងប្រទេសកម្ពុជា</td><td>គ្មាន</td><td>-៦០% ចំពោះសំបុត្រកុន 2D<br>-៦០% ចំពោះសំបុត្រកុន 3D<br>-៦០% ចំពោះសំបុត្រកុន VIP</td><td>០១ មីនា ២០២៥ ដល់ ៣១ ឧសភា ២០២៥</td></tr>
</table>

| | | | |
|---|---|---|---|
| រាល់ការទិញសំបុត្រកុន តាមម៉ាស៊ីនឆូតកាត ដោយប្រើប្រាស់ប័ណ្ណធនាគារ ព្រីនស៍ ដូចជាប័ណ្ណ UPI MasterCard និង Visa (ទាំងប័ណ្ណឥណពន្ធ/ប័ណ្ណឥណទាន)<br>(ថ្ងៃសុក្រ ដល់ថ្ងៃអាទិត្យ) | គ្រប់សាខារោងកុន Major Cineplex ក្នុងប្រទេសកម្ពុជា | - ត្រឹមតែ ៥ ដុល្លារ សម្រាប់កញ្ចប់ សំបុត្រកុន 2D + ពោតផ្ទុះ (ចំនុះ៤៦oz-ទំហំតូច) + កូកាកូឡា (ចំនុះ ២២ oz - ទំហំតូច)<br>-ត្រឹមតែ ៥ ដុល្លារ សម្រាប់កញ្ចប់ សំបុត្រកុន 3D + ពោតផ្ទុះ(ចំនុះ៤៦oz-ទំហំតូច) + កូកាកូឡា(ចំនុះ ២២ oz - ទំហំតូច) | ០១ មីនា ២០២៥ ដល់ ៣១ ឧសភា ២០២៥ |
| * សំគាល់៖ ការបញ្ចុះតម្លៃប្រើប្រាស់បានតែម្តងសម្រាប់ប័ណ្ណមួយក្នុងមួយថ្ងៃប៉ុណ្ណោះ។ | | | |

៣. ការផ្តល់ជូនជាការបញ្ចុះតម្លៃ នឹងត្រូវបានផ្តល់ជូនអ្នកចូលរួម ដោយអនុលោមតាម បញ្ញត្តិ និងលក្ខខណ្ឌនេះ នៅក្នុងរយៈពេលកម្មវិធីលើកទឹកចិត្ត ឬរហូតដល់ពេលដែលគម្រោងថវិកាដែលត្រូវបានអនុម័តសម្រាប់កម្មវិធីលើកទឹកចិត្តនេះ ត្រូវបានចំណាយអស់។

៤. ក្នុងករណីមានការឆបោក ឬក្លែងបន្លំដែលប្រព្រឹត្តដោយ ឬមានពាក់ព័ន្ធនឹងអ្នកចូលរួមទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ អ្នកចូលរួមរូបនោះនឹងបាត់បង់សិទ្ធិចូលរួមកម្មវិធីលើកទឹកចិត្តនេះ ដោយរួមទាំងអត្ថប្រយោជន៍ផ្សេងៗដែលខ្លួនទទួលបាន។ អ្នកចូលរួមត្រូវប្រគល់មកវិញជូនធនាគារ ព្រីនស៍ នូវរាល់អត្ថប្រយោជន៍ដែលខ្លួនបានទទួលពីធនាគារ ព្រីនស៍ តាមរយៈកម្មវិធីលើកទឹកចិត្តនេះ (ប្រសិនបើមាន) និងត្រូវសងសំណងការខូចខាតផ្សេងៗទៅតាមបញ្ញត្តិច្បាប់ជាធរមាន។

៥. ការរក្សាសិទ្ធិ ការរួចផុត និងការកម្រិតនៃការទទួលខុសត្រូវ

ក. អ្នកចូលរួម យល់ព្រមថា ធនាគារ ព្រីនស៍ រួមបញ្ចូលទាំង ម្ចាស់ភាគហ៊ុន អភិបាល ឬបុគ្គលិករបស់ ធនាគារ ព្រីនស៍ មិនត្រូវទទួលខុសត្រូវលើ រាល់ការខូចខាតណាមួយ ទោះដោយផ្ទាល់ ឬដោយប្រយោល ជាពិសេស ឬដោយចៃដន្យ ដែលកើតឡើងទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះឡើយ។

ខ. អ្នកចូលរួម យល់ព្រមដោយមិនដកវិញថា អ្នកចូលរួមយល់ព្រមសងសំណង និងធានាថាធនាគារ ព្រីនស៍ នឹងទទួលបានសំណងគ្រប់ពេលណាមួយ លើរាល់ការបាត់បង់ ការខូចខាត កម្រៃសេវា កម្រៃសេវាផ្លូវច្បាប់ និងការចំណាយផ្សេងៗ និងរាល់វិបាកដែលកើតឡើងលើ ធនាគារ ព្រីនស៍ ឬបានទទួលរងដោយ ធនាគារ ព្រីនស៍ ចំពោះការទាមទារ ឬបណ្តឹងណាមួយដែលធ្វើឡើងដោយអ្នកចូលរួម ឬភាគីទីបី ដែលកើតឡើង ឬទាក់ទងនឹងបញ្ញត្តិដែលមានចែងក្នុងបញ្ញត្តិនិងលក្ខខណ្ឌនេះ។

គ. ធនាគារ ព្រីនស៍ មិនទទួលខុសត្រូវទោះក្នុងទម្រង់ណាមួយចំពោះការខូចខាត ឬការខាតបង់ដែលកើតចេញពីប្រតិបត្តិការរវាងអ្នកចូលរួម និងរោងកុន Major Cineplex ឡើយ។

៦. ធនាគារ ព្រីនស៍ រក្សាសិទ្ធិគ្រប់យ៉ាង ក្នុងការធ្វើវិសោធនកម្មលើបញ្ញត្តិនិងលក្ខខណ្ឌនេះ ពន្យាពេល បន្ថែមរយៈពេល ឬលុបចោលកម្មវិធីលើកចិត្តនេះ និង/ឬការផ្តល់ជូន នៅពេលណាមួយក្នុងរយៈពេលកម្មវិធីលើកទឹកចិត្តដោយមិនមានការទទួលខុសត្រូវ តាមឆន្ទានុសិទ្ធិដាច់ខាតរបស់ធនាគារ ព្រីនស៍ ដោយគ្រាន់តែផ្តល់ការជូនដំណឹងពីការផ្លាស់ប្តូរ នៅលើគេហទំព័រផ្លូវការ ឬតាមមធ្យោបាយទំនាក់ទំនងផ្សេងទៀតរបស់ធនាគារ ព្រីនស៍។

៧. បញ្ញត្តិនិងលក្ខខណ្ឌនេះ ត្រូវបានគ្រប់គ្រងដោយច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ រាល់វិវាទដែលកើតឡើង ឬទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ នឹងត្រូវបានដោះស្រាយ ដោយអនុលោមតាមគោលនយោបាយដោះស្រាយបណ្តឹងអតិថិជនរបស់ធនាគារ និងតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។